Minnesota Department of Education

Special Education Compliance and Assistance:

dMeNaH¨sayCemÂaH

Minnesota Department of Education Home Page - MDE Programs - Special Education - Due Process Resources

education.state.mn.us ខែមេសា 2008

របៀបដាក់ពាក្យបណ្តឹងលើការអប់រំពិសេស

ឯកសារនេះ ពន្យល់ពីរបៀបដាក់ពាក្យបណ្តឹង ជាមួយ Minnesota Department of Education (MDE-ក្រសួងអប់រំ រដ្ឋ Minnesota) អំពីការប្រព្រឹត្តរំលោភណាមួយ លើច្បាប់ ឬបញ្ញត្តិ ការអប់រំពិសេស ។ ប្រព័ន្ធ នៃការដាក់ពាក្យបណ្តឹងគឺមិនបាច់ចំណាយប្រាក់ឡើយ ហើយអាចជាវិធីមួយផ្សេងទៀត ចំពោះដំណើរការសវនាការ ដែលឈានចូលដល់ថ្ងៃកំណត់ ។

ជំហានដែលត្រូវអនុវត្ត មុនពេលដាក់ពាក្យបណ្តឹង : នៅមុនពេលដាក់ពាក្យបណ្តឹង MDE សូមជំរុញមាតាបិតា ឬអ្នកដទៃទៀត ឱ្យទំនាក់ទំនងជាមុន ជាមួយនឹងនាយកមណ្ឌលសិក្សា សំរាប់ការអប់រំពិសេស ដែលជាមនុស្សអាចជួយដោះស្រាយបញ្ហាជូនបាន ។ អ្នកអាចទំនាក់ទំនងនាយកមណ្ឌលសិក្សារបស់អ្នកបាន តាមរយៈ http://education.state.mn.us/WebsiteContent/SpecEdDirectors.jsp ។

នរណាអាចដាក់ពាក្យបណ្តឹងលើការអប់រំពិសេសបាន? មនុស្សគ្រប់រូប ដោយរួមទាំងអង្គការផង អាចដាក់ពាក្យបណ្តឹងលើការអប់រំពិសេសបាន ។

ហេតុអ្វីបានជាត្រូវដាក់ពាក្យបណ្តឹង? ពាក្យបណ្តឹងអាចត្រូវដាក់ប្តឹងបាន ចំពោះអង្គភាពណាមួយ ដែលផ្តល់សេវាអប់រំ ដល់សិស្ស ដោយបានទទួលជំនួយពីមូលនិធិថវិការដ្ឋ ដែលត្រូវបានគេចោទប្រកាន់ថា បានប្រព្រឹត្តរំលោភ ច្បាប់ ឬបញ្ញត្តិអប់រំពិសេសរបស់រដ្ឋ ឬរបស់សហព័ន្ធ ក្នុងរយៈពេលមួយឆ្នាំ លើកាលបរិច្ឆេទ ដែលបណ្តឹងត្រូវបានបញ្ជូនទៅដល់ MDE ។ ប្រសិនបើអ្នកមិនប្រាកដថា ការព្រួយបារម្ភរបស់អ្នកជារឿងសមរម្យ អ្នកអាចទាក់ទងជាមួយនឹងអង្គការតស៊ូមតិ ឬ MDE ដើម្បីរកជំនួយក្នុងការសំរេច ថាអ្នកគួរដាក់ពាក្យប្តឹងឬទេ ។ បញ្ជីឈ្មោះ អង្គការផ្តល់ការតស៊ូមតិ អាចរកអានបានតាមរយៈ http://www.nichcy.org/stateshe/mn.htm - disability ។

តើការបារម្ភបែបណាដែលមាតាបិតា លើកឡើងអំពីសេវាអប់រំពិសេសរបស់កូនពួកគេ តាមរយៈដំណើរការបណ្តឹង? ប្រព័ន្ធបណ្តឹងលើការអប់រំពិសេស ត្រូវបង្កើតឡើងដើម្បីធានាថា សិស្សពិការទាំងអស់ បានទទួលនូវការអប់រំសាធារណៈដែលមានភាពសមរម្យ ដោយមិនបាច់បង់ប្រាក់ ។ ខាងក្រោម គឺជាឧទាហរណ៍ នៃប្រភេទបញ្ហាដែល MDE បានដោះស្រាយ តាមរយៈប្រព័ន្ធបណ្តឹង :

- តើមណ្ឌលសិក្សាស្រុក បានផ្តល់សេវាអប់រំពិសេស ដែលត្រូវការ ដល់សិស្សពិការដែរឬទេ?
- តើមណ្ឌលសិក្សាស្រុក បានអប់រំសិស្ស ក្នុងបរិយាកាសដែលមានភាពតឹងតែងតិចដែរឬទេ?
- តើមណ្ឌលសិក្សាស្រុក ខកខានមិនបានរកឱ្យឃើញ នូវសិស្សដែលមានពិការភាពដែរឬទេ?
- តើមណ្ឌលសិក្សាស្រុក ព្យួរ ឬបញ្ឈប់សិស្សពីសាលា ញឹកញាប់ ដែលវារំខានដល់ការអប់រំរបស់សិស្សដែរឬទេ?
- តើសិស្សបានទទួលនូវ សេវាការបន្ទាយឆ្នាំសិក្សារបស់សាលាដែរឬទេ?

របៀបដាក់ពាក្យបណ្តឹង : អ្នកត្រូវផ្ញើសំណើរបណ្តឹង ដោយមានចុះហត្ថលេខា រួមទាំងពត៌មានពិតជាក់លាក់ ក្នុងការគាំទ្រលើបណ្តឹង ដែលថា ភ្នាក់ងារអប់រំ បានប្រព្រឹត្តរំលោភ លើភាពតម្រូវរបស់ ច្បាប់ ឬបញ្ញត្តិ អប់រំពិសេសរបស់រដ្ឋ ឬសហព័ន្ធ ជាមួយនឹងសំណើរចំពោះដំណោះស្រាយ លើការប្រព្រឹត្តរំលោភដែល រងការចោទប្រកាន់ ។ ក្នុងពាក្យបណ្តឹងនេះ ត្រូវមានសរសេរនូវអាស័យដ្ឋាន និងលេខទូរស័ព្ទរបស់អ្នក ឈ្មោះ និងអាស័យដ្ឋានរបស់កូនអ្នក ព្រមទាំងឈ្មោះ និងអាស័យដ្ឋានរបស់សាលាដែលកូនអ្នកចុះឈ្មោះចូលរៀន ។ អ្នកត្រូវតែបញ្ជូននូវសំណៅថតចម្លងមួយច្បាប់នៃពាក្យបណ្តឹង មកកាន់មណ្ឌលសិក្សាស្រុកផងដែរ ។

កន្លែងដែលត្រូវបញ្ជូន ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ និងចុះហត្ថលេខាទៅកាន់ : អ្នកត្រូវផ្ញើពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ ដោយទូរសារទៅកាន់លេខ (651.582.8725), ដោយអ៊ីម៉ែល ឬកាន់ដោយផ្ទាល់ទៅកាន់ :

Due Process Supervisor
Minnesota Department of Education
Division of Compliance and Assistance
1500 Highway 36 West
Roseville, MN 55113-4266

តើ MDE ធ្វើអ្វីខ្លះ ពេលបានទទួលបណ្តឹង?

- ពេលដែល MDE បានទទួលបណ្តឹងជាលាយល័ក្ខណ៍អក្សររួចហើយ គេនឹងបញ្ជូនវាទៅកាន់អ្នកស៊ើបអង្កេតលើពាក្យបណ្តឹង ដែលត្រូវយកពាក្យបណ្តឹងជាលាយល័ក្ខណ៍អក្សរនោះ មកពិនិត្យ ដើម្បីកំណត់លើបញ្ហាដែលត្រូវចុះស៊ើបអង្កេត ។
- អ្នកស៊ើបអង្កេតលើពាក្យបណ្តឹង នឹងទំនាក់ទំនងជាមួយនឹងម្ចាស់បណ្តឹង ដើម្បីផ្ញើសំបុត្រទៅកាន់អ្នកនោះ ក្នុងការបញ្ជាក់លើការបានទទួលបណ្តឹងរួចហើយ ព្រមទាំងដើម្បីពិភាក្សាលើការទាមទារ ការពិត ឬបញ្ហា ហើយអាចកែតម្រូវពាក្យបណ្តឹង ដោយយោងលើការពិភាក្សានេះ ។
- អ្នកស៊ើបអង្កេតលើពាក្យបណ្តឹង នឹងផ្ញើលិខិតមួយទៅកាន់ភ្នាក់ងារសាធារណៈ ដោយមានន័យាយលំអិត នូវអ្វីដែលមានសរសេរ ក្នុងបណ្តឹងដើម និងពត៌មានថ្មីៗណាមួយ ឬការចោទប្រកាន់ ចេញពីការពិភាក្សា ជាមួយអ្នកដាក់ពាក្យបណ្តឹង ។
- អ្នកស៊ើបអង្កេតលើពាក្យបណ្តឹង នឹងទំនាក់ទំនងជាមួយ នាយកការអប់រំពិសេស ដើម្បីរកមើលថា បញ្ហាដែលបានចោទប្រកាន់ អាចដោះស្រាយបានតាមបែបក្រៅផ្លូវការ ។
- អ្នកស៊ើបអង្កេតពាក្យបណ្តឹង នឹងផ្តល់ឱកាសឱ្យភ្នាក់ងារសាធារណៈ ក្នុងការលើកនូវសំណើរដើម្បីជាដំណោះស្រាយ លើការចោទប្រកាន់ ក៏ដូចជាផ្តល់ឱកាសឱ្យមាតាបិតា ដែលបានដាក់ពាក្យបណ្តឹង ឱ្យចូលរួមដោយស្ម័គ្រចិត្ត ក្នុងការផ្សះផ្សារ ជាមួយភ្នាក់ងារសាធារណៈ ។
- ក្នុងពេលធ្វើការស៊ើបអង្កេត អ្នកស៊ើបអង្កេតលើពាក្យបណ្តឹង នឹងធ្វើនូវចំណុចដូចខាងក្រោម ក្នុងកិច្ចការផ្សេងៗ ដូចជា :
  1. ទំនាក់ទំនងជាមួយបុគ្គលិក របស់ភ្នាក់ងារអប់រំ ដើម្បីសុំពត៌មានបន្ថែម ឬជួយក្នុងការដោះស្រាយ ចំពោះបញ្ហាដែលចោទប្រកាន់ ។
  2. ផ្ញើលិខិត ដល់អ្នកដែលដាក់ពាក្យបណ្តឹង ដោយសរសេរជូននូវបញ្ហា ដែល MDE នឹងចុះស៊ើបអង្កេត ។
  3. កំណត់ថា តើការស៊ើបអង្កេត ត្រូវឱ្យមានទំនាក់ទំនងតាមទូរស័ព្ទ ស្នើសុំឱ្យមានការសរសេរជាឯកសារ ចុះទៅពិនិត្យដល់ទីកន្លែង សំភាសន៍ ប្រឹក្សាយោបល់ជាមួយអ្នកជំនាញការអប់រំ ឬវិធីផ្សេងទៀតដែលត្រូវការ ដើម្បីដោះស្រាយបណ្តឹងឱ្យបានទទួលជោគជ័យ ។
- អ្នកស៊ើបអង្កេតលើពាក្យបណ្តឹង នឹងពិនិត្យលើគ្រប់ពត៌មានពាក់ព័ន្ធទាំងអស់ រួចហើយធ្វើការកំណត់ដោយឯករាជ្យ លើចំណុចដែលថា តើភ្នាក់ងារអប់រំបានប្រព្រឹត្ត រំលោភលើច្បាប់ ឬបញ្ញត្ត៖ របស់រដ្ឋ ឬសហព័ន្ធដែរឬទេ ។

តើ MDE ត្រូវប្រើពេលយូរប៉ុណ្ណា ក្នុងការដោះស្រាយបណ្តឹងមួយ? MDE មានពេល ៦០ថ្ងៃ ក្នុងការដោះស្រាយបណ្តឹងមួយ ។ រយៈពេលនេះ គិតចាប់ពីថ្ងៃដែល MDE បានទទួលពាក្យបណ្តឹងជាលាយល័ក្ខណ៍អក្សរ ។ ចំពោះស្ថានភាពពិសេសណាមួយ MDE អាចពន្យារយៈពេលនេះឱ្យលើសពី ៦០ថ្ងៃបាន ។ រយៈពេលកំណត់ ៦០ថ្ងៃនេះ ក៏អាចពន្យារបានដែរ ប្រសិនបើ ភាគីទាំងពីរ យល់ព្រម ចូលរួមលើការផ្សះផ្សារដោយស្ម័គ្រចិត្ត ឬចូលរួមក្នុងវិធីក្រៅតុលាការផ្សេងទៀត ក្នុងការដោះស្រាយជំលោះ ។

តើខ្ញុំអាចបានទទួលនូវលទ្ធផលនៃការស៊ើបអង្កេតដោយរបៀបណា? MDE នឹងសរសេរលិខិត ចំពោះការសំរេចចិត្តចុងក្រោយ ហើយផ្ញើសំណៅថតចម្លងមួយច្បាប់ទៅកាន់ម្ចាស់ដើមបណ្តឹង និងមួយច្បាប់ទៀតទៅកាន់ ភ្នាក់ងារអប់រំដែលរងការចោទប្រកាន់ ។ សេចក្តីសំរេចចិត្តចុងក្រោយ នឹងមានប្រសិទ្ធិភាព នៅពេលសរសេរចេញជាផ្លូវការហើយត្រូវតែអនុវត្តតាម ។

តើនឹងមានអ្វីកើតឡើង ប្រសិនបើ MDE រកមិនឃើញនូវការប្រព្រឹត្តរំលោភណាមួយបានកើតឡើងទេ? ប្រសិនបើ MDE រកមិនឃើញនូវការប្រព្រឹត្តិរំលោភណាមួយកើតឡើងទេ ក្រោយពីធ្វើការស៊ើបអង្កេតរួចហើយ បណ្តឹងនេះ ត្រូវបិទ នៅពេលដែលគេចេញនូវសេចក្តីសំរេចចិត្តជាចុងក្រោយរួចហើយ ។

តើនឹងមានអ្វីកើតឡើង ប្រសិនបើ MDE រកឃើញការប្រព្រឹត្តិរំលោភច្បាប់បានកើតឡើង? ប្រសិនបើ ភ្នាក់ងារអប់រំ បានប្រព្រឹត្តិរំលោភ ដែលតម្រូវឱ្យមានចំណាត់ការ ដើម្បីកែតម្រូវ MDE នឹងរៀបចំនូវផែនការសកម្មភាព សំរាប់កែតម្រូវ ដែលត្រូវសរសេរបញ្ជូលទៅក្នុងការសំរេចចិត្តចុងក្រោយ ។ សកម្មភាពកែតម្រូវ ដោះស្រាយនូវអំពើឈឺចាប់ណាមួយចំពោះសិស្ស ដោយការផ្តល់នូវ កម្មវិធីបន្ថែម ឬការអប់រំ ដើម្បីជាការប៉ះប៉ូវ ។ សកម្មភាពកែតម្រូវ ក៏ដោះស្រាយផងដែរនូវ ការមិនធ្វើតាមរបស់ស្រុក ដូចជា ការតម្រូវឱ្យមានការបណ្តុះបណ្តាលដល់បុគ្គលិក ។ ភ្នាក់ងារអប់រំដែលទទួលខុសត្រូវ ត្រូវតែធ្វើឱ្យបានចប់នូវ សកម្មភាពកែតម្រូវ ឱ្យបានតាមពេលដែលបានកំណត់ឱ្យ ។ MDE នឹងធ្វើការតាមដាន ជាមួយនឹងភ្នាក់ងារអប់រំ និងជាមួយម្ចាស់បណ្តឹង ដើម្បីរកឱ្យឃើញថា សកម្មភាពកែតម្រូវ បានធ្វើរួចរាល់តាមពេលកំណត់ ។ប្រសិនបើ ភ្នាក់ងារអប់រំ ខកខានមិនបានបញ្ចប់សកម្មភាពកែតម្រូវទេ MDE នឹងចាត់វិធានការដោយខ្លួនឯង ដើម្បីធានាថា បញ្ហាត្រូវបានដោះស្រាយ ។

តើអាចធ្វើអ្វីបានទៀត ប្រសិនបើភ្ញានភាគីណាមួយពេញចិត្តចំពោះលទ្ធផលស៊ើបអង្កេតរបស់ MDE ទេនោះ? អ្នកប្តឹង ឬភ្នាក់ងារអប់រំអាច ធ្វើ**បណ្តឹង**ឧទ្ធរទៅកាន់ Minnesota Court of Appeals (តុលាការ ឧទ្ធររបស់រដ្ឋ Minnesota) ក្នុងរវាង ៦០ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលនូវការសំរេចចិត្ត ចុងក្រោយ ។

តើបណ្តឹងអាចបន្តបានទេ ប្រសិនបើខ្ញុំ យល់ព្រមចំពោះ ការផ្សះផ្សារ? អាចបន្តបាន . MDE ត្រូវតែបន្តធ្វើការស៊ើបអង្កេត លើពាក្យបណ្តឹង បើ អ្នក ឬភ្នាក់ងារអប់រំ មិនយល់ព្រមក្នុងការពន្យារពេលកំណត់ សំរាប់ពាក្យបណ្តឹង ដើម្បីចូលរួមក្នុងដំណើរការផ្សះផ្សារ ។